អង្គរបុរី
សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ ក្រោមប្រធានបទ បុគ្គលត្រូវសម្លាប់កិលេសតណ្ហា ដែលជាហេតុនាំឲ្យមានទុក្ខ មិនត្រូវសម្លាប់ខ្លួន ដើម្បីចេញចាកទុក្ខឡើយ ។

website: www.hoksavann.org
ថ្ងៃទី២១ តុលា ២០០៧



កាលពីព្រឹកថ្ងៃ៥ កញ្ញា ២០០៧ មានព្រះសង្ឃខ្មែរមួយអង្គនៅស្រុកព្រៃឈរខេត្តកំពង់ចាម ព្រះនាមហេង-ប៊ុនឆោម ព្រះជន្ម២៨ឆ្នាំ បានធ្វើអត្តឃាតដោយដុតខ្លួននៅក្នុងព្រះវិហារ ក្នុងអាការៈគង់ធ្វើសមាធិ ។ តាមអ្នករាយការណ៍ពត៌មានថា គេរកឃើញលិខិតមួយនៅក្នុងបន្ទប់សឹងរបស់លោក ក្នុងលិខិតនោះសរសេរថា អាត្មាបានដុតខ្លួនបូជាព្រះធម៌ សូមញាតិញោមអនុមោទនាផងចុះ ។ តាមថេរដីការបស់ព្រះសង្ឃដែលគង់នៅវត្តថា ព្រះភិក្ខុហេង-ប៊ុនឆោម មុននឹងដុតព្រះកាយតែងតែពោលអំពីព្រះធម៌និងសេចក្តីស្លាប់ ហើយមានខ្សែអាត់ទេសនាលោកប៊ុត-សាវង្សជាប់នឹងខ្លួនលោក ។ ការដុតខ្លួននេះ ទំនងធ្វើសមាធិបែកឆ្វេង គឺប្រតិបត្តិខុសផ្លូវព្រះធម៌ ។

ដើម្បីយល់អំពីការសម្លាប់ខ្លួនបូជាធម៌ ជាការត្រឹមត្រូវតាមធម៌វិន័យរបស់ព្រះពុទ្ធសាសនា ឬពុំត្រឹមត្រូវនោះ សូមយល់អំពីកិច្ចក្នុងអរិយសច្ច៤ ដែលព្រះអរិយបុគ្គលទាំង៤ពួកគឺ ព្រះសោតា ព្រះសកិទាគាមី ព្រះអនាគាមី និងព្រះអរហន្ត បានកំណត់ក្នុងព្រះទ័យដោយលោកុត្តរបញ្ញា គឺទុក្ខសច្ចៈ ប្រែថា សេចក្តីពិតគឺទុក្ខ បានដល់ការកើតឡើងនៃខន្ធ៥មានរូបខន្ធជាដើម ជាតួទុក្ខ ។ បានសេចក្តីថា ការកើតឡើងនៃរូបរាងកាយចិត្តវិញ្ញាណរបស់មនុស្សសត្វជាទុក្ខ បាលីថា បញ្ចុប្បាទានក្ខន្ធា ទុក្ខា ប្រែថា សេចក្តីទុក្ខកើតមាន ព្រោះការកើតឡើងនៃខន្ធប្រាំ ឬការមានជាតិ ។ សេចក្តីទុក្ខ គឺខន្ធ៥នេះត្រូវកំណត់

ដឹង គឺត្រូវកំណត់ថា ខន្ធ៥ជាតួទុក្ខ បាលីថាបរិញ្ញោយ្យកិច្ច គឺកិច្ចគប្បីកំណត់ដឹង ពុំមែនសម្លាប់ខ្លួន ឬលះបង់ខ្លួន ដើម្បីសំរេចធម៌ ឬដើម្បីនិព្វាននោះឡើយ នេះជាអរិយសច្ចទីមួយ ។ អរិយសច្ចទីពីរ គឺសមុទយសច្ច ប្រែថា សេចក្តីពិត គឺហេតុដែលនាំឲ្យកើតទុក្ខ ឬហេតុដែលនាំឲ្យកើតទុក្ខជាសេចក្តីពិត បានដល់តណ្ហាជាហេតុនាំឲ្យមានទុក្ខ ឬតណ្ហា សេចក្តីប្រាថ្នា ជាហេតុនាំឲ្យមានជាតិមានខន្ធ៥ ដែលជាតួទុក្ខ ។ តណ្ហានេះទើបជាមហាតព្វកិច្ច គឺកិច្ចដែលត្រូវលះបង់ឬត្រូវសម្លាប់ គឺសម្លាប់តណ្ហាដែលស្ថិតនៅក្នុងចិត្តពុំមែនសម្លាប់រូបរាងកាយឡើយ ។ កាលណាសម្លាប់តណ្ហាដែលជាហេតុ ខន្ធ៥ជាផលក៏ពុំកើតមានឡើយ ។ អរិយសច្ចទី៣ គឺនិរោធសច្ច ប្រែថា ការរលត់ទុក្ខជាសេចក្តីពិត ។ និរោធសច្ច ជាសច្ឆិកាតព្វកិច្ច ជាកិច្ចដែលត្រូវធ្វើឲ្យជាក់ច្បាស់ គឺធ្វើឲ្យកើតឡើងនូវការរំលត់ទុក្ខ ។ អរិយសច្ចទី៤ គឺមគ្គសច្ច ប្រែថា ផ្លូវប្រតិបត្តិដើម្បីរំលត់ទុក្ខជាសេចក្តីពិត បានដល់មគ្គប្រកបដោយអង្គ៨ មានសម្មាទិដ្ឋិ ប្រែថាការយល់ត្រូវជាដើម ។ មគ្គសច្ចនេះជាភាវេតព្វកិច្ច គឺជាកិច្ចត្រូវចំរើនឲ្យកើតឡើង គឺត្រូវប្រតិបត្តិតាមមគ្គទាំង៨ ដែលរួមមកបានដល់សីលសមាធិនិងបញ្ញា ។ ដូចបានពោលមកហើយ ទុក្ខសច្ច សេចក្តីទុក្ខជាការពិត បានដល់ការកើតឡើងនៃរូបរាងកាយជាតួទុក្ខ ត្រូវកំណត់ដឹង ពុំត្រូវលះបង់ឬសម្លាប់ឡើយ ឯធម្មជាតិដែលត្រូវសម្លាប់គឺតណ្ហា ដែលស្ថិតនៅក្នុងចិត្តទើបពុំមានជាតិដែលនាំឲ្យមានព្យាធិនិងមរណៈតទៅទៀត ។ ដូច្នេះព្រះភិក្ខុហេង-ប៊ុនឆោម ដែលធ្វើអត្តឃាតដុតខ្លួននោះ ពុំត្រឹមត្រូវតាមធម៌វិន័យឡើយ ។ ក្នុងព្រះវិន័យនិយាយថា ភិក្ខុសម្លាប់មនុស្ស ត្រូវអាបត្តិបារាជិកសម្លាប់ខ្លួនឯងត្រូវអាបត្តិទុក្កដ ។ ពិតមែនតែការសម្លាប់ខ្លួនត្រូវអាបត្តិទុក្កដ ជាអាបត្តិមានទោសស្រាល ក៏ព្រះពុទ្ធហាមមិនឲ្យសម្លាប់ខ្លួនដែរ ក្នុងសម័យពុទ្ធកាល មានភិក្ខុជាច្រើនអង្គ បានចំរើនកាយគតាសតិ គឺពិចារណានូវរូបរាងកាយ មានកេសាសក់លោមារោមនខាក្រចកជាដើម ថាជារបស់មិនស្អាត គួរខ្ពើមរអើម ក៏កើតធម៌នេះឡើង ក៏កើតការនឿយណាយ ក៏ធ្វើអត្តឃាតខ្លួនឯងខ្លះ ឲ្យគេសម្លាប់ខ្លះ ។ លុះជ្រាបដល់ព្រះពុទ្ធ ទើបព្រះអង្គត្រាស់ឲ្យគេហៅ ភិក្ខុដែលសេសសល់ពីសុគតមកទូន្មានថា ម្នាលភិក្ខុទាំងឡាយ អ្នកប្រព្រឹត្តធ្វើដូច្នេះ ជាការប្រព្រឹត្តខុស អ្នកមិនត្រូវសម្លាប់ខ្លួនឡើយ តែត្រូវសម្លាប់រាគៈ ការត្រេកអរស្រឡាញ់ជាប់ចិត្ត នូវរូបរាងកាយដែលជារបស់មិនស្អាតនោះវិញទេ ។ សូម្បីព្រះអរហន្ត ដែលលោកបានសំរេចជាព្រះអរហត្ត កំចាត់កិ-លេសតណ្ហាអស់ហើយ ទោះបីលោកមានការធុញទ្រាន់នឹងខន្ធ៥ ក៏លោកមិនធ្វើគតខ្លួនលោកឡើយ គឺទុក្ខឲ្យខន្ធ៥នេះត្រូវរលត់ គឺត្រូវស្លាប់ដោយខ្លួនឯង ។

ពាក្យថា ធ្វើសមាធិបែកឆ្វេង បានជាយល់ខុសធ្វើអត្តឃាតខ្លួនឯង បានសេចក្តីថា ប្រតិបត្តិខុសបំណងរបស់សមាធិឬវិបស្សនា ។ ត្រង់នេះហើយបានជាព្រះពុទ្ធសាសនា បានពោលថា ធុរៈឬកិច្ចដែលពុទ្ធសាសនិកជនត្រូវអនុវត្តមានពីរប្រការ គឺគន្ថធុរៈ ការ

សិក្សាឲ្យយល់ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ បើសមាធិ និងវិបស្សនា ត្រូវសិក្សាឲ្យយល់របៀបចំរើន ។ ធុរៈទីពីរ គឺវិបស្សនាធុរៈ ត្រូវប្រតិបត្តិតាមរហូតឃើញសេចក្ដីពិតជាខន្ធ៥ជាអនិច្ចំ ទុក្ខំ និងអនត្តា ។ បើពុំបានសិក្សាយល់ច្បាស់លាស់ អាចប្រតិបត្តិខុស និងប្រើចិត្តខុសឃ្លាតពីព្រះធម៌ ។ សមាធិ ប្រែថា ភាពរបស់ចិត្ត និងចេតសិក ជាកុសល ដែលដឹកលប់ស្មើល្អក្នុងអារម្មណ៍តែមួយ ។ ចិត្តធម្មតាដែលមិនទាន់កើតសមាធិ មានអកុសល៥យ៉ាងស្ថិតនៅក្នុងចិត្តបិទបាំងរារាំង ដែលហៅថា នីវរណធម៌ គឺ កាមច្ឆន្ទៈ ការនឹកគិតទៅរកកាមមានរូបជាដើម ព្យាបាទ ៖ ចិត្តចងគំនុំអ្នកដទៃ ថីនមិទ្ធៈ ចិត្តរួញរាទុទ្ធច្ចកុក្កុច្ចៈ ចិត្តរាយមាយ និងវិចិកិច្ឆា ចិត្តសង្ស័យ ។ កាលណាសមាធិចិត្តកើតឡើង នីវរណធម៌ទាំង៥នេះត្រូវស្ងប់ ។ ការចំរើនឲ្យកើតសមាធិចិត្ត គឺដើម្បីធ្វើចិត្តឲ្យស្ងប់ពីនីវរណធម៌នេះឯង ។ បំណងរបស់សមាធិកម្មដ្ឋាន គឺចេតោវិមុត្តិ ប្រែថាការឃើញច្បាស់នូវខន្ធ៥ មានរូបខន្ធជាដើម មិនទៀង ជាទុក្ខ និងជាអនត្តា ។ សីលសមាធិនិងបញ្ញាមានទំនាក់ទំនងគ្នា ដែលចេញមកពីមគ្គប្រកបដោយអង្គ៨ មានសម្មាទិដ្ឋិ ការយល់ត្រូវជាដើម ជាផ្លូវប្រតិបត្តិ ដើម្បីទៅកាន់ទីរំលត់ទុក្ខ ។ ផ្លូវប្រតិបត្តិនេះហើយដែលអាចឆ្លុះបញ្ចាំងឃើញខន្ធ៥របស់មនុស្សសត្វ ជាតួទុក្ខដែលនាំឲ្យចិត្តនឿយណាយ ទើបឃើញគុណសម្បត្តិរបស់ព្រះនិព្វានជាគុណជាតិចេញចាកទុក្ខ ។ នេះជាបំណងពិតរបស់សមាធិនិងវិបស្សនាប្រតិបត្តិ ដើម្បីដកចិត្តចេញពីសង្ខារធម៌មានខន្ធ៥ជាដើម ។ ព្រះធម៌របស់ព្រះពុទ្ធសាសនាប្រតិបត្តិដើម្បីលះបង់លោភៈ ទោសៈ មោហៈ អវិជ្ជាជាដើម ។ ការប្រតិបត្តិនាំឲ្យជាប់ចិត្តនឹងអ្វីមួយដែលជាចំណីតណ្ហា ការប្រតិបត្តិបែបនេះ ពុំត្រឹមត្រូវតាមព្រះធម៌របស់ព្រះពុទ្ធសាសនាឡើយ ព្រោះធ្វើហេតុនាំឲ្យមានទុក្ខ (តណ្ហាជាហេតុការកើតឡើងនៃខន្ធ៥ជាទុក្ខ) ។ ព្រះភិក្ខុហេង-ប៊ុនឆោមដែលធ្វើអត្តឃាតខ្លួនឯង ទំនងប្រតិបត្តិខុសដោយមានចំណេះខាងព្រះពុទ្ធសាសនាតិតតួច យល់ពុំច្បាស់លាស់ផ្លូវប្រតិបត្តិ បានជាមានគំនិតខុស ដែលហៅថាបែកឆ្វេង រហូតធ្វើអត្តឃាតខ្លួនឯង ។៚

❊ ❊

❊